TOR Tuluncke: (visit). (1)

D119778 DC-Cam

# CGP SITE FORM

Site Name ..Km 4.. Khmer ..គីឡូម៉ែត្រ ៤.. ID No........ Date........

Province ..Stung Treng.. District ..Stung Treng..
Sub-District ..Stung Treng.. Village ..Reachea Nokol.. Khmer ..រាជនគរ..

**Prison**
__Interrog Ctr.
__Previous Prison
__Purpose Built
__School
__Wat
__House
__Other

**Burial Site**
__Pit
__Kiln
__Rice paddy
__River/lake
__Well
__Execution
__Other

**Memorial**
__Wat
__Stupa
__Brick/tile
✓ Wooden
__Other

**Access:**
Route No ..to Ratanak Kiri.. 5 Km from ..Stung Treng Provincial town.. Condition ..fair (4WD is required)..

Route No......... ........Km from ........ Condition........

**Estimated No of Victims** ..1000+.. **Mass graves** ..9..

**Contact Persons (Official)** ..Min San — or Som Sitha Head of CPP, Stung Treng —

**Visited:** (Yes) / No **Team :** ..YNK..

**Photos:** Roll # ........ Shots # ........

**Documents:** ..Yes (Collected from CPPHQ)..

**Interviews:** ..Yes —..

**Comments:** ..Memorial needs to be took care of. ~~I chose found two documents which discussing on that matter~~..

**Latitude:** N ..13° 30' 04.54".. **Longitude:** E ..~~105~~ 105° 58' 11.64"..

**File No:** ..R052607B.. **Time:** ........

For future Re: (visit). ②

# CGP SITE FORM

Site Name: Chong Hong lake  Khmer: [Khmer handwriting]  ID No.  Date: 26-5-97

Province: Stung Treng  District: Stung Treng
Sub-District: Stung Treng  Village: Reachea NoKol  Khmer: [Khmer handwriting]

**Prison**
__Interrog Ctr.
__Previous Prison
__Purpose Built
__School
__Wat
__House
__Other

**Burial Site**
__Pit
__Kiln
__Rice paddy
✓ River/lake (Killing Site).
__Well
__Execution
__Other

**Memorial**
__Wat
__Stupa
__Brick/tile
__Wooden
__Other

**Access:**
Route ~~No.~~ To Ratanak Kiri  5 Km from Stung Treng Provincial Town  Condition: fair (4WD is required)

Route No.  Km from  Condition

**Estimated No of Victims** ≃ 1000  **Mass graves**

**Contact Persons (Official)** Som Sophen or Min Sam
Address: Phum Reachea NoKol, Khum Stung Treng, Srok Stung Treng

**Visited:** (Yes) / No  **Team:** Youk

**Photos:** Roll #  Shots #

**Documents:** N/A

**Interviews:** Yes

**Comments:** Chong Hong lake is known to almost everyone in Stung Treng as a "Big" Killing Site during the Democratic Kampuchea.

**Latitude:** N 13° 30' 05.06"  **Longitude:** E 105° 58' 16.05"

**File No:** 19052607A  **Time:**

# CGP SITE FORM

Site Name: Kham Vieng House **Khmer**: ផ្ទះខាំវៀង **ID No.**

**Date**

**Province**: Stung Treng **District**: Stung Treng

**Sub-District**: Stung Treng **Village**: Renchen Nokol **Khmer**

**Prison**
- ✓ Interrog Ctr.
- __Previous Prison
- __Purpose Built
- __School
- __Wat
- ✓ House
- __Other

N 13°30'13"
E 150°58.0677"
R 052700A

**Burial Site**
- ✓ Pit
- __Kiln
- __Rice paddy
- __River/lake
- __Well
- __Execution
- __Other

**Memorial**
- __Wat
- __Stupa
- __Brick/tile
- __Wooden
- __Other

**Access**: to Ratanak

Route No. Kiri- 5 Km from Stung Treng Provincial Town Condition fair (4WD is required)

Route No......... .........Km from ........................Condition..................

**Estimated No of Victims** 2000 **Mass graves** 50

**Contact Persons (Official)** Gen. Heng Saman who is living next to the prison -

**Visited**: (Yes) / No **Team**: YNK

**Photos**: Roll # ............ Shots # ..............................

**Documents**: N/A

**Interviews**: Yes -

**Comments**: shall return to search a mass graves during summer. (May be in June)

**Latitude**: N. 13°50'0589 **Longitude**: E. 105°58'0914"

**File No**: R052608A **Time**:

# ខេត្តស្ទឹងត្រែង និងអំពើប្រល័យពូជសាសន៍

## ស្រាវជ្រាវដោយ ឆាំង យុ

## " ១៥-១៩ តុលា ១៩៩៥ "

**កំណត់សំគាល់**

មុនពេលធ្វើដំណើរទៅកាន់ខេត្តស្ទឹងត្រែង បណ្ឌិត **ហេឡិន ចាវីស** ទីប្រឹក្សាផ្នែកឯកសារនៃកម្មវិធីស្រាវជ្រាវអំពីការប្រល័យពូជសាសន៍នៅកម្ពុជា បានផ្តល់យោបល់ថាខ្ញុំគួរតែសួរពត៌មាន ជាមុនសិនអំពី សាស្ត្រាចារ្យប្រវត្តិវិទ្យានៃសកលវិទ្យាល័យភ្នំពេញ **អ៊ីង ច័ន** ដែលធ្លាប់បានទៅទីនោះ ម្តងរួចមកហើយ ។

ខ្ញុំបានទៅជួបជាមួយលោកសាស្ត្រាចារ្យនៅឯផ្ទះរបស់គាត់នៅវេលាម៉ោង ៧:៣០យប់ ។ លោកសាស្ត្រាចារ្យ **អ៊ីង ច័ន** បានរាយការណ៍ថា លោកបានទៅធ្វើការស្រាវជ្រាវនៅទីនោះ កាលពីឆ្នាំ១៩៩៤ ប៉ុន្តែលោកស្នាក់នៅខេត្តស្ទឹងត្រែងតែមួយយប់ទេ ព្រោះគោលដៅរបស់លោកដែលធ្វើដំណើរទៅកាន់ភូមិភាគឥសាននេះ គឺដើម្បីធ្វើសំភាសន៍ជាមួយអតីតខ្មែរក្រហម ម្នាក់នៅខេត្តរតនៈគីរី ។ ទោះជាយ៉ាងណាក៏ដោយលោកបានរាយការណ៍ថា នៅខេត្តស្ទឹងត្រែងមានកន្លែងប្រល័យពូជសាសន៍តែមួយគត់ គឺស្ថិតនៅចំកណ្តាលក្រុងនៃខេត្តស្ទឹងត្រែងតែម្តង និងមានគុករបស់ខ្មែរក្រហមមួយដែរ ប៉ុន្តែឥឡូវនេះសំណង់ថ្មី បានសង់ពីលើ ជាយូរឆ្នាំមកហើយ ។

**អំពីខេត្តស្ទឹងត្រែង និងប្រជាជន :**

ខេត្តស្ទឹងត្រែង ជាខេត្តមួយមានទីតាំងនៅ ប្របនឹងទន្លេមេគង្គ ប៉ែកឥសាននៃព្រះរាជាណាចក្រកម្ពុជា ។ តាមស្ថិតិខេត្តស្ទឹងត្រែងឆ្នាំ១៩៩៥ បានអោយដឹងថា ខេត្តមានប្រជាជនទាំងអស់ចំនួន ៧១២៥៤ នាក់ ដែលត្រូវជា ១២៨៧៨ គ្រួសារ រស់នៅក្នុងភូមិចំនួន ១២៨ ឃុំចំនួន ៣៤ នៃស្រុកទាំង៥ គឺ ស្រុកស្ទឹងត្រែង ស្រុកថាឡាបរិវ៉ាត់ ស្រុកសៀមបូក ស្រុកសេនសាន និងស្រុកសៀមប៉ាង ។ ក្នុងចំណោមជនជាតិភាគតិចទាំងអស់ ក្រៅពីជនជាតិវៀតណាម ឡាវ ចាម និងចិននោះ ខេត្តស្ទឹងត្រែង មានជនជាតិដើមចំនួន ៨ក្រុម ទៀត គឺ គ្រឹង ចំនួន ២១០នាក់, ទំពួន ចំនួន ៣នាក់, ព្រៅ ចំនួន ៣៧០នាក់, ព្នង ចំនួន ៦៤៧នាក់, ចារ៉ាយ ចំនួន ១៧នាក់, លុន ចំនួន ២៨១នាក់, កាវ៉ែត ចំនួន ១៩៤នាក់ និងគួយ ចំនួន ២៧៨ នាក់ ។ ខេត្តស្ទឹងត្រែងត្រូវបានពួកខ្មែរក្រហមក្រោមផ្លាករណសិរ្សបង្រួបបង្រួមជាតិ រំដោះយកបានតាំងពីក្រោយថ្ងៃ ១៨ មិនា ឆ្នាំ១៩៧០ មកម្លេះ ។

យោងតាមឯកសារ ដែលចងក្រងដោយ មន្ទីររណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ចុះក្នុងខែសីហា ឆ្នាំ១៩៨៣ បានអោយដឹងថា នៅខេត្តស្ទឹងត្រែង មានប្រជាជនចំនួន ២១៩៨នាក់ ដែលត្រូវបានសម្លាប់ដោយពួកខ្មែរក្រហម ។ ក្នុងចំណោមនោះមានកសិករ ៤៨៦នាក់ កម្មករ និងរដ្ឋការស៊ីវិល ៦៩០នាក់, ព្រះសង្ឃ ៣១អង្គ និងជនជាតិភាគតិចចំនួន ៤៦០នាក់ ។ ឯកសារដដែលនេះ បានបញ្ជាក់ថា មានប្រជាជនចំនួន ២៦នាក់ បានធ្លាក់ខ្លួនពិការ ធ្វើការពុំកើត ។ ស្ថិតិសរុបនៃទីតាំងប្រល័យពូជសាសន៍រួមមានរណ្តៅ ប្រហែល ៥៩រណ្តៅ ក្នុងភូមិ រាជានុកូល គុក ៥កន្លែងសម្លាប់មនុស្ស ៩ និងសារមន្ទីរ១ ដែលបានរកឃើញបច្ចុប្បន្ន ។

នៅក្នុងយន្តហោះធ្វើដំណើរទៅកាន់ខេត្តស្ទឹងត្រែង ខ្ញុំបានជួបជាមួយឯកឧត្តម **អ៊ឹម សុទ្ធី** តំណាងរាស្ត្រខេត្តកំពង់ចាម និងជាវាគ្មិនសកម្មម្នាក់ក្នុងឱកាសសន្និសិទ្ធអន្តរជាតិ ដែលរៀបចំឡើងដោយសកលវិទ្យាល័យយ៉េល ក្នុងថ្ងៃទី ២១-២២ ខែសីហា ឆ្នាំ១៩៩៥ ។ ឯកឧត្តម **សុទ្ធី** ធ្វើដំណើរទៅកាន់រតនៈគីរី ហើយបានជួបពតិមានថា នៅខេត្តរតនៈគីរីមានរណ្តៅសាកសពជាច្រើន ។ មេឃភ្លៀងខ្លាំងនៅពេលយន្តហោះចុះនៅខេត្តស្ទឹងត្រែង ។ ខ្ញុំបានជួបបណ្ណាញនៅទីនោះ ហើយបានសម្រេចជ្រើសរើសយកគេជាអ្នកបើកបររថយន្ត ។

**អំពីអ្នកបើកបររថយន្ត :** " រូបថតភ្ជាប់ជាមួយ "

**ថោង សារ៉ុម** ភេទ ប្រុស កើតនៅឆ្នាំ១៩៦៥ ស្រុកកំណើតនៅខេត្តស្វាយរៀង បានមករស់នៅក្នុងខេត្តស្ទឹងត្រែង ក្នុងឆ្នាំ១៩៨៤ ។

**អ្នកដឹកនាំខេត្តស្ទឹងត្រែង បច្ចុប្បន្នរួមមាន :**

១- លោកអភិបាលខេត្ត **លី ស៊ូ** *(FUNCINPEC)* ទូរស័ព្ទលេខ ៥៨៨១១

២- លោកអភិបាលរងទី១ **នួន ប៉ែន** *(CCP)* ទូរស័ព្ទលេខ ៥៨៨១៣

៣- លោកអភិបាលរងទី២ **ហេង គីម** *(FUNCINPEC)* ទូរស័ព្ទលេខ ៥៨៨១០

៤- លោកអភិបាលរងទី៣ **ក្មុយ សារឹម** *(CCP)* ទូរស័ព្ទលេខ ៥៨៨១៥

លោក **នួន ប៉ែន** ជាអតីត អនុរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុក្នុងរដ្ឋកម្ពុជា ។ ដោយមូលហេតុថាលោកអភិបាលខេត្ត និងលោកអភិបាលខេត្តរងទី១ អវត្តមាន ខ្ញុំបានសម្រេចជួបជាមួយ លោក **ក្មុយ សារឹម** ដើម្បីអនុវត្តការស្រាវជ្រាវ ទីតាំងសព និងឯកសារដែលពាក់ព័ន្ធនឹងការប្រល័យពូជសាសន៍ ។

## ទីតាំងប្រល័យពូជសាសន៍

**១. បឹង ចោងហោង** " វាលសម្លាប់មនុស្ស-រូបថតភ្ជាប់ជាមួយ "

ស្ថិតនៅក្នុងភូមិគីឡូម៉ែត្រ ៤ " សព្វថ្ងៃមានឈ្មោះថា ភូមិរាជនុកូល " ឃុំស្ទឹងត្រែង ស្រុកស្ទឹងត្រែង ។

<u>សាក្សីទី១</u> " រូបថតភ្ជាប់ជាមួយ " លោក **សោម សោភា** អាយុ ៤០ឆ្នាំ ស្រុកកំណើតនៅស្រុកស្ទោង ខេត្តកំពង់ធំ ។ គាត់បានមករស់នៅខេត្តស្ទឹងត្រែង ក្នុងឆ្នាំ១៩៨៤ ។ ក្នុងសម័យ **ប៉ុល ពត** គាត់រស់នៅភូមិត្រពាំងវែង ឃុំស្រយ៉ូវ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ គាត់បានរាយការណ៍ថា គាត់បានឃើញសាកសពអណ្តែតទឹកនៅក្នុងបឹង ហើយកាលនោះ កងទ័ពវៀតណាម និងរដ្ឋអំណាចខេត្តបានប្រមូលសាកសពនៅទីនេះ និងឆ្អឹងទៅគរទុកនៅក្នុងរោងមួយខាងមុខផ្ទះគាត់សព្វថ្ងៃ ។ បឹងចោងហោង មានទីតាំង នៅពីក្រោយ ផ្ទះរបស់គាត់ ។

<u>សាក្សីទី២</u> " រូបថតភ្ជាប់ជាមួយ " លោក **មិន សន** អាយុ ៧០ឆ្នាំ ជាអ្នកមូលដ្ឋានចាស់ ។ គាត់មានកូន ៨នាក់ រស់នៅជាមួយសព្វថ្ងៃ ក្នុងភូមិ រាជានុកូល ឃុំស្ទឹងត្រែង ស្រុកស្ទឹងត្រែង ។ ប្រវត្តិរូបសង្ខេបរបស់គាត់មានដូចតទៅ :

- ១៩៧០ - ១៩៧៣ ជាទាហានរបស់ **លន់ ណុល** ឋានៈពលទោស

- ១៩៧៣ - " ៧៤? " រួមចលនាតស៊ូជាមួយខ្មែរក្រហម ហើយបានទៅរស់នៅតំបន់ញ៉ើន ស្រុកឈូក ខេត្តកំពត នៅខាងលិច ឃុំត្រពាំងអណ្តើក ។ គាត់ជាអ្នកយាមគុកលេខ ២០៤ ។ គុក ២០៤ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់មជ្ឈិមបក្ស ដែលមានទីតាំងនៅក្នុងតំបន់ ៣៥ នៃភូមិភាគនិរតី " ៤០៥ " ។

- ១៩៧៥ អង្គការបញ្ជូនមកខេត្តស្ទឹងត្រែង ។ គាត់រស់នៅក្នុងភូមិស្រែគ ឃុំស្រែគ ស្រុកសេសាន ។ គាត់បានរាយការណ៍ថា យ៉ាងហោចណាស់មានមនុស្សប្រហែល ១០០០នាក់ ត្រូវបានពួកខ្មែរក្រហមយកមកសម្លាប់នៅបឹងចោងហោងនេះ ។

**២. កន្លែងតំកល់សព :** " ទល់មុខបឹងចោងហោង - រូបថតភ្ជាប់ជាមួយ "

អ៊ុំ **សន** បានរាយការណ៍ថា នៅខាងក្រោយកន្លែងតំកល់សព ដែលស្ថិតនៅក្នុងភូមិរាជានុកូលនេះដែរ មានរណ្តៅធំៗប្រហែល ៩ ដែលបានរកឃើញនៅក្នុងឆ្នាំ១៩៧៩ ។ ទីតាំងនេះ មិនអាចចូលជិតបាន ដោយព្រៃដុះរុំព័ទ្ធជុំវិញ ហើយសត្វពស់ប្រហែលជារស់នៅក្បែរនោះទៀតផង ។ ប៉ុន្តែអាចមើលឃើញពីចំងាយបាន ។

គាត់បានរាយការណ៍ថា " តា **សិលា** " ដែលជាប្រធានឈ្លបស្រុកស្ទឹងត្រែងនេះ គឺជាអ្នកនាំអ្នកទោសមកកាន់មន្ទីរឃុំឃាំង នៅខាងលិចបឹងចោងហោងនេះ ។ គុកនោះមានឈ្មោះថា គុកតំបន់ ១០៥ ។ គួរកត់សំគាល់ថា តំបន់ ១០៥ គឺជាតំបន់មណ្ឌលគិរី ស្ថិតនៅក្នុងខេត្តមណ្ឌលគិរី " សូមមើលផែនទីកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៦ " ។ វាពុំច្បាស់ថា តើគុកនេះដាក់មនុស្សមកពីភូមិភាគឥសាន ឬ តំបន់ណាខ្លះទេ ។ ប៉ុន្តែវាច្បាស់ថា គុកនេះត្រូវបានត្រួតត្រាដោយមេខ្មែរក្រហមម្នាក់មកពីតំបន់មណ្ឌលគិរី ។

## ៣. **គុក** : " រូបថតភ្ជាប់ជាមួយ "

<u>សាក្សី</u> : វរៈសេនីយ៍ត្រី **ហេង សាម៉ាន** អាយុ ៤០ឆ្នាំ មានមុខងារជាប្រធានការិយាល័យស៊ើបអង្កេតទី២ *(2BI)* នៃកងយោធពលខេមរភូមិន្ទ សព្វថ្ងៃរស់នៅក្នុងភូមិរាជនុកូល ។ ក្នុងសម័យ **ប៉ុល ពត** រស់នៅព្រំប្រទល់ដែនខេត្តក្រចេះ និងកំពង់ចាម " ភូមិភាគបូព៌ា " ។ មនុស្សដែលធ្លាប់រស់នៅក្នុងផ្ទះរបស់គាត់ បច្ចុប្បន្ននេះ គឺជាអតីតមេសន្តិសុខខ្មែរក្រហម ។ គាត់បានរាយការណ៍ថា មេសន្តិសុខនៅទីនោះឈ្មោះ **ខាំ ទៀង** ជាជនជាតិភាគតិច មកពីតំបន់មណ្ឌលគិរី និងជាជនដៃដល់ក្នុងការសម្លាប់មនុស្សក្នុងតំបន់ ១០៥នេះ ។ គាត់បានគិតថា **ខាំ ទៀង** ប្រហែលជាស្លាប់បាត់ទៅហើយ ក្នុងការប្រយុទ្ធមួយរវាងរដ្ឋកម្ពុជា និងក្រុមខ្មែរក្រហម កាលពីឆ្នាំ ១៩៨៩ នៅខេត្តមណ្ឌលគិរី ។

## ៤. **រណ្តៅ** : " រូបថតភ្ជាប់ជាមួយ "

នៅពីក្រោយផ្ទះលោក **សាម៉ាន** មានរណ្តៅសពប្រហែល ៥០ ។ កូនទាហានរបស់គាត់ធ្លាប់បាចត្រី ហើយប្រទះឃើញក្បាល ឆ្អឹង លលាដ៏ រាប់មិនអស់ ។ មានរណ្តៅមួយចំនួនទៀតពុំទាន់បានគាស់នៅឡើយទេ ។ បច្ចុប្បន្ននេះ ទឹកលិចគ្រប់រណ្តៅ ។ គាត់សំណូមពរអោយមកមើលជាក់ស្តែងម្តងទៀតក្នុងរដូវប្រាំង ។ គាត់បាននិយាយថា មានអ្នកស្រុកមកលួចគាស់រណ្តៅនេះរកមាស និង កំណាប់ ផ្សេងៗ ដែលគេជឿជាក់ថា មានជាប់នៅលើខ្លួនអ្នកទោស ។

លោក **សាម៉ាន** ពុំដែលឮពាក្យ សន្តិបាលទេ ប៉ុន្តែសន្តិសុខ ដែលប្រហែលជាទាក់ទងនឹងសកម្មភាពការពារតាមមូលដ្ឋានតែប៉ុណ្ណោះ ។

## **ឯកសារប្រល័យពូជសាសន៍** : " រូបថតភ្ជាប់ជាមួយ "

ជួបជាមួយលោក **ស៊ុំ សុថា** អាយុ ៥៩ឆ្នាំ ប្រធានគណបក្សប្រជាជនកម្ពុជា ខេត្តស្ទឹងត្រែង និងជាអតីតអភិបាលខេត្តស្ទឹងត្រែង រវាងឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៩២ ក្នុងគោលដៅស្វែងរកឯកសារផ្សេងៗ

ដែលទាក់ទងទៅនឹងការកាប់សម្លាប់មនុស្សក្នុងខេត្តស្ទឹងត្រែង ។ ឯកសារមួយចំនួនដែលទាក់ទងទៅនឹងការថ្កោលទោស អំពើប្រល័យពូជសាសន៍មកលើប្រជាជនខេត្តស្ទឹងត្រែង ត្រូវបានរកឃើញ និងថតចំលងទុកជាឯកសារនៅឯមជ្ឈមណ្ឌលឯកសារ ។

**ពត៌មាន** : " រូបថតភ្ជាប់ជាមួយ "

ជួបជាមួយព្រះតេជគុណ **ម៉ែន សារិន** ព្រះជន ៦៣វស្សា គង់នៅវត្តភ្នំស្ទឹងត្រែង " សង់ក្នុងថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩៥ " ក្នុងឃុំស្ទឹងត្រែង ស្រុកស្ទឹងត្រែង ។ ព្រះតេជគុណមានស្រុកកំណើតនៅភូមិប្រាសាទ ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។ ប្រវត្តិរូបសង្ខេបមានដូចតទៅ :

- ១៩៥៤-១៩៥៧ ទាហានបារាំង នៅព្រៃវែង
- ១៩៥៧-១៩៦៤ ផ្លាស់មកភ្នំពេញ ក្នុងអង្គភាពវិស្វកម្មយោធា
- ១៩៦៩- ផ្លាស់មកនៅខេត្តស្ទឹងត្រែង ក្នុងអង្គភាពដដែល
- ១៩៧០- នៅពេលដែលខ្មែរក្រហមរំដោះបានខេត្តស្ទឹងត្រែង លោកបាននិមន្តទៅរស់នៅភូមិអូស្វាយ ឃុំអូស្វាយ " បច្ចុប្បន្ន មានឈ្មោះថា ឃុំព្រះរំលៃ " ស្រុកស្ទឹងត្រែង " បច្ចុប្បន្នមានឈ្មោះថា ស្រុកថាឡាបរិវ៉ាត់ " ។
- ១៩៧៩-១៩៨៧ ធ្វើជាប្រធានភូមិអូស្វាយ
- ១៩៨៧ បួសជាសង្ឃ

ព្រះតេជគុណបានរាយការណ៍ថា គណៈស្រុកស្ទឹងត្រែង កាលនោះឈ្មោះ **តាយ៉ាន** ក្រោយមកជំនួសដោយ **តាមី** ជនជាតិភាគតិច ។ បានរាយការណ៍ទៀតថា កាលនោះ ខ្មែរក្រហមសម្លាប់ជនជាតិអាមេរិកាំង ២រូប នៅភូមិអូស្វាយ ក្នុងឆ្នាំ១៩៧០ ។ រាយការណ៍ថា ក្នុងឆ្នាំ១៩៧១, ១៩៧២, ១៩៧៣ ពុំមានការសម្លាប់ច្រើនទេ នៅខេត្តស្ទឹងត្រែង ។ មានការសម្លាប់តិចតួចណាស់ លើករណីលួចម្ហូបអាហារ ឬខុសសីលធម៌តែប៉ុណ្ណោះ ។ ក្នុងឆ្នាំ១៩៧៥ មានប្រជាជន ១៧ មេសា ប្រហែល ៣-៤ គ្រួសារ បានមកដល់ភូមិអូស្វាយ ហើយក្រោយមកត្រូវបានពួកខ្មែរក្រហម សម្លាប់ចោលទាំងអស់ ។ ព្រះតេជគុណបានរាយការណ៍ថា ក្នុងឆ្នាំ១៩៧៥ មានពួកនិរតីមកកាន់កាប់ ខេត្តស្ទឹងត្រែង ។

បាននិយាយថា ខ្មែរក្រហមគួរតែត្រូវបានផ្តន្ទាទោស ។

**សន្តិសុខ** : " រូបថតភ្ជាប់ជាមួយ "

ជួបជាមួយលោកអភិបាលរងទី៣ **កុយ សារីម** ដើម្បីសុំកំលាំងសន្តិសុខការពារ និងឯកសារពីរណ្ដៅសព ។ អំពីនគរបាលការពារ ១- **ហិម វិបុល** អាយុ ២៧ឆ្នាំ ស្រុកកំណើត នៅខេត្តស្វាយរៀង បានរត់គេចពីកំណែនកងទ័ព "ក៥" មកខេត្តស្ទឹងត្រែងក្នុងឆ្នាំ ១៩៨៧ ។ ២- **ថន វឌ្ឍមុនី** អាយុ ២៧ឆ្នាំ ស្រុកកំណើតនៅខេត្តក្រចេះ ហើយបានមករស់នៅក្នុងខេត្តស្ទឹងត្រែង ក្នុងឆ្នាំ១៩៨២ ។

**ទីតាំងប្រល័យពូជសាសន៍ :** " រូបថតភ្ជាប់ជាមួយ "

**១. ភូមិ អូររមាត** ឃុំអូររមាត ស្រុកសៀមប៉ាង ។

សាក្សី : អ្នកស្រី **ស៊ី សាវី** អាយុ ៥២ឆ្នាំ សព្វថ្ងៃធ្វើការនៅគណៈបក្សប្រជាជនកម្ពុជា ខេត្តស្ទឹងត្រែង ។ មានកូន ៧នាក់ ប្អូនថ្លៃរបស់គាត់ត្រូវបានពួកខ្មែរក្រហម យកមកដាក់គុកនៅខេត្តស្ទឹងត្រែង ឆ្នាំ១៩៧៣ ហើយមានសមាជិកគ្រួសារចំនួន ៩នាក់ទៀត ត្រូវបានពួកខ្មែរក្រហមសម្លាប់ ។ ចូរកត់សំគាល់ថាគុករបស់ខ្មែរក្រហមដែលស្ថិតនៅក្នុងទីរួមខេត្តស្ទឹងត្រែងបច្ចុប្បន្ននេះ គឺជាធនាគារខេត្ត ។

**២. គុក :** " រូបថតភ្ជាប់ជាមួយ "

សាក្សី : លោក **ចាប ច័ន្ទជីវ័ន្ត** អាយុ ៤៩ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិអូចាឡុង ឃុំស្រែក្រសាំង ស្រុកស្ទឹងត្រែង ។ លោកបានរាយការណ៍ថា កន្លែងឃុំឃាំងមានបី នៅក្នុងខេត្តស្ទឹងត្រែង :

- ធនាគារបច្ចុប្បន្ន ជាកន្លែងឃុំឃាំង
- មន្ទីរបសុពេទ្យជាកន្លែងសួរចម្លើយ ក្នុងឆ្នាំ១៩៧២ - ១៩៧៣
- សណ្ឋាគារកុលាបស្ទឹងត្រែងជាកន្លែងសួរចម្លើយក្នុងឆ្នាំ១៩៧០-១៩៧៥ និងជាឃ្លាំងដាក់អំបិល

**៣. កន្លែងសម្លាប់នៅអូរពងមាន់ :**

អូរពងមាន់ ជាចំណុចបំបែកនៃខេត្តក្រចេះ ស្ទឹងត្រែង និងរតនៈគីរី ។ លោក **ជីវ័ន្ត** បានរាយការណ៍ថា គណៈស្រុក ៤៣ ឈ្មោះ **ខាំ ឡុន** ក្នុងឆ្នាំ ១៩៧៨ ។ ១៩៧០ - ៧៣ - ៧៥ ស្ទឹងត្រែងហៅថាតំបន់ស្ទឹងត្រែង ។ រាយការណ៍ថា ក្នុងឆ្នាំ១៩៧១ មនុស្ស ២០នាក់ ត្រូវបានពួកខ្មែរក្រហមចាប់ខ្លួន និងបញ្ជូនទៅមន្ទីរសួរចម្លើយ " ធនាគារបច្ចុប្បន្ន " ហើយបន្ទាប់មកយកទៅសម្លាប់នៅអូរពងមាន់ ។

**ឯកសារ :**

ស្រាវជ្រាវនៅការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈ

លោក **សំ សារអែម** ប្រធានតាំងពីឆ្នាំ១៩៨៤

លោក **សុវ៉ាន ណារ៉ា** ឯកសារ

លោក **លី ស៊ឿន** អនុប្រធាន

ឯកសារពាក្យបណ្តឹងស្តីអំពីការបាត់បង់សមាជិកគ្រួសារក្នុងរបបខ្មែរក្រហម ត្រូវបានរកឃើញ និងថតចំលងទុកជាឯកសារនៅឯមជ្ឈមណ្ឌលឯកសារ ។

**ពត៌មាន :** " រូបថតភ្ជាប់ជាមួយ "

** ក្នុងឆ្នាំ១៩៧៣-១៩៧៤ ពុំមានការកាប់សម្លាប់រង្គាលទេ ប៉ុន្តែមានការសម្លាប់ដោយជំរើស និងមានការបែងចែកប្រភេទមនុស្ស ។ លោក **មួន** បានជឿថា ខ្មែរក្រហមបានប្តូរឈ្មោះពីរណសិរ្សរួបរួមជាតិ មកជាកម្ពុជាប្រជាធិបតេយ្យ នៅក្នុងឆ្នាំ១៩៧៥ ។

## ទីតាំងប្រល័យពូជសាសន៍ ឆ្នាំ១៩៧៥-១៩៧៦ :

លោក **មួន** រាយការណ៍ថា :

១- **ភូមិបាច** ឃុំដូង ស្រុកថាឡាបរិវ៉ាត់ មានមនុស្សប្រហែល ៣០០០នាក់ ដែលខ្មែរក្រហមយកទៅសម្លាប់នៅទីនោះ ។

២- **ភូមិកំបោរ** ឃុំអូរ ស្រុកថាឡាបរិវ៉ាត់ មានមនុស្សប្រហែល ២០០០នាក់ ដែលខ្មែរក្រហមយកទៅសម្លាប់ទីនោះ ។

** ភូមិបាច និង ភូមិកំបោរ ស្ថិតនៅចម្ងាយ ២០គីឡូម៉ែត្រ ពីទីរួមខេត្តស្ទឹងត្រែង ហើយបច្ចុប្បន្ន នេះជាតំបន់ឆ្លងកាត់របស់ពួកខ្មែរក្រហម ។ ប្រធានភូមិបាច ឈ្មោះ **ម៉េន** និង ប្រធានសន្តិសុខ ឈ្មោះ **សុខ** ។ ប្រធានភូមិកំបោរពុំស្គាល់ឈ្មោះទេ ។

** ពាក្យថា សន្តិសុខ ប្រហែលសំដៅទៅលើ ការការពារសណ្តាប់ធ្នាប់តាមភូមិ ឃុំ ហើយពាក្យសន្តិបាល ពុំដែលធ្លាប់ឮទេ ។

** អ្នកដែលទទួលខុសត្រូវក្នុងការបញ្ជូនមនុស្សទៅសម្លាប់នៅភូមិកំបោរ និង ភូមិបាច មានពីររូប ដែលបច្ចុប្បន្ននេះរស់នៅជាមួយគ្នាជាប្តីប្រពន្ធ : ១- **ញ៉ៀម សុខន** ហៅ **ម៉េង** អតីត: គណៈស្រុកសៀមបូករបស់ខ្មែរក្រហម ២- **ស៊ិន នីចាន់** ហៅ **ផា** ប្រធាននារីស្រុកសៀមបូក ។ អ្នកទាំងពីរនេះ សព្វថ្ងៃរស់នៅភូមិក្រោម ឃុំព្រះរំកិល ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ។ ភូមិក្រោមមានទីតាំងស្ថិតនៅ ប្រហែល ៣គីឡូម៉ែត្រ ពីភ្នំ

ខោន ព្រំប្រទល់ដែនឡាវ ទល់មុខនឹងភូមិអូរស្វាយដែលជាកន្លែង ពួកខ្មែរក្រហមសម្លាប់ជនជាតិអាមេរិកាំង ២រូប ក្នុងឆ្នាំ១៩៧០ ។ ពីទីរួមខេត្តស្ទឹងត្រែង ទៅកាន់ភូមិក្រោមត្រូវធ្វើដំណើរតាមទូកមានរយៈពេល ៤ម៉ោង ។

**ពត៌មានអំពីការសម្លាប់ជនជាតិអាមេរិកាំង :** " រូបថតភ្ជាប់ជាមួយ "

ជនដែលពាក់ព័ន្ធនៅក្នុងរឿងឃាដកម្មនេះ ឈ្មោះ **មៅ ថានី** សព្វថ្ងៃរស់នៅភូមិអូរស្វាយ " អតីត ប៉ារ៉ាចូលសារភាពក្នុងឆ្នាំ១៩៨៩ " ។ មានសេចក្តីរាយការណ៍ថា ជនជាតិអាមេរិកាំង ទាំង ២រូប នោះជាប្រុសម្នាក់ និងស្រីម្នាក់ ។ ជនជាតិអាមេរិកាំង ភេទ ប្រុស នោះនៅពេលដែលបានឃើញយោធាខ្មែរក្រហមចាប់រំលោភលើមិត្តភក្តិស្រីរបស់ខ្លួន ក៏បានរត់ទៅបុកដើមឈើសម្លាប់ខ្លួនឯង ។ កាលពីឆ្នាំ ១៩៩៤ កន្លងទៅនេះ មានក្រុមអ្នកស្រាវជ្រាវរកជនជាតិអាមេរិកាំង បាត់ខ្លួននៅកម្ពុជា បានទៅដល់ភូមិអូស្វាយនេះតាមយន្តហោះ ដោយមានការជួយឧបត្ថម្ភ ផ្នែកសន្តិសុខពីអភិបាលខេត្តស្ទឹងត្រែងផង ។ ការស្រាវជ្រាវនេះពុំបានលទ្ធផលទេ ។ អ្នកសង្កេតការនៅទីនោះបានរាយការណ៍ថា ក្រុមស្រាវជ្រាវពុំមានប្រភពពតិមានច្បាស់លាស់ ហើយធ្វើការស្រាវជ្រាវរករណ្តៅសព តែក្នុងរយៈពេល ២ម៉ោង តែប៉ុណ្ណោះ ។

បទសម្ភាសន៍ជាមួយវរៈសេនីយ៍ត្រី **កោះ មួន** អាយុ ៤១ឆ្នាំ អតីតៈប្រធានឃោសនាគណបក្សហ៊ុនស៊ិនប៊ិច បច្ចុប្បន្នជានាយកការិយាល័យ អង្គភាពសាលាទាហានទី១ ខេត្តស្ទឹងត្រែង រស់នៅក្នុងភូមិមណ្ឌល៤ ឃុំស្ទឹងត្រែង ស្រុកស្ទឹងត្រែង ។ ប្រវត្តរូបសង្ខេបមានដូចតទៅ :

- ១៩៦២-១៩៧០ បំរើកងទ័ព **សីហនុ** បន្ទាប់មក **លន់ ណុល**

- ១៩៧០-១៩៧២ ជាកសិករ រស់នៅក្នុងភូមិ សៀមបូក ឃុំសៀមបូក ស្រុកសៀមបូក

- ១៩៧២ បំរើកងឈ្លបឃុំ របស់ខ្មែរក្រហមនៅភូមិសៀមបូក

- ១៩៧៣ បំរើអោយកងទ័ពខ្មែរក្រហម ទីតាំងនៅភូមិត្រពាំងគល់ ឃុំត្រពាំងគល់ ស្រុកដូនទន់ ខេត្តព្រះវិហារ កាន់អាវុធ សេ កា សេ ។

- ១៩៧៣-១៩៧៥ បានបំរើអស់រយៈពេល ៦ខែ នៅក្នុងជួរកងទ័ពខ្មែរក្រហម ។ បន្ទាប់មកអង្គការបានបញ្ជូនទៅក្នុងអង្គភាពនេសាទ ស្រុកសៀមបូក ពីព្រោះដោយសារគាត់ចេះមុជទឹក ។ អង្គភាពនេសាទនេះ ជាអង្គភាពផលិត នៃមន្ទីរ ស២៧ ។

** " ស " ពុំមែនមានន័យថា " សន្តិសុខ " ទេ ហើយក៏មិនដែលឮពាក្យថា សន្តិបាលដែរ ។ " ស ២៧ " ស្ថិតនៅក្នុងតំបន់ ១០៣ ខេត្តព្រះវិហារ ។ ប្រធានតំបន់ឈ្មោះ " **តា ម៉ាន** " ក្រោយមកពួកខ្មែរក្រហមយកទៅសម្លាប់ចោល ។

- ១៩៧៦ ត្រឡប់ទៅអង្គភាពទន្លេសាបតំបន់ ១០៣ វិញ " ជាជំរើសអ្នកមុជទឹក " ទីតាំងនៅមាត់ស្ទឹងសែន ទន្លេផុក " ភូមិសាស្ត្រ? " ។

- ១៩៧៧ ខ្មែរក្រហមមកពីនិរតី បានចាប់ប្រធានតំបន់ ១០៣ " **តាហុឌុ** អាយុ ៤៧ឆ្នាំ ជាតិខ្មែរ " យកទៅសម្លាប់ចោល ដោយចោទថា មានទំនាក់ទំនងជាមួយនឹងវៀតណាម ។ ក្រោយមកគ្រប់អង្គភាពទាំងអស់ ក្រោមការគ្រប់គ្រងរបស់ " **តាហុឌុ** " ត្រូវបានរំលាយចោល ។ កម្មាភិបាលទាំងអស់ត្រូវបានអោយត្រឡប់មកកាន់ភូមិកំណើតរបស់ខ្លួនវិញ ។ គាត់បានត្រឡប់ទៅ កាំងចាប " កាំង ចាម " ឃុំកាំងចាប ស្រុកថាឡាបរិវ៉ាត់ ហើយបានរៀបការនឹងប្រពន្ធរបស់គាត់ ។

- ១៩៧៩ កងទ័ពវៀតណាមបានមកដល់ ប្រពន្ធរបស់គាត់ស្លាប់ដោយសារជំងឺ ។ គាត់បានផ្លាស់ទៅនៅភូមិអូរម្រះ ឃុំអូរម្រះ ស្រុកសៀមបូកវិញ ។

- ១៩៧៩ ចូលបំរើកងទ័ពរដ្ឋកម្ពុជា ។

- ១៩៨១-៨៦ រត់ទៅនៅជំរំបក្សីចាំក្រុង បំរើជាអង្គរក្សរបស់លោក **ប៉ែន ថាល់** នៅជំរំណាំយឺន " លោក **ប៉ែន ថាល់** ជាកូនប្រុសទី២ របស់សម្តេចជ្វាវាំង **ប៉ែន នុត** អតីតៈនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ១៩៤៥ ដល់ ឆ្នាំ១៩៧០ និងជាប្អូនប្រុសរបស់ឯកឧត្តម **ប៉ែន ថុល** បច្ចុប្បន្នជាតំណាងរាស្ត្រខេត្តកំពង់ស្ពឺ នៃគណបក្ស ប្រជាធិបតេយ្យសេរីនិយម ព្រះពុទ្ធ សាសនា " ។

- ១៩៨៦-៨៩ រស់នៅជំរំសាយប៊ី " ដោយមូលហេតុថា ឈ្មោះ **កែវ ជួន** ហៅ **កែវ សាវុធ** ប្រធានជំរំណាំយឺន រកសម្លាប់លោក **ប៉ែន ថុលា** និងខ្លួនគាត់ ។ **កែវ ជួន** បច្ចុប្បន្នធ្វើការនៅក្រសួងធម្មការ ខេត្តព្រះវិហារ " ។

- ១៩៩៣ ប្រធានរៀបចំការបោះឆ្នោត ខេត្តស្ទឹងត្រែង នៃគណបក្សហ្វ៊ុនស៊ិនប៉ិច

**សាលាស្រុកថាឡាបរិវ៉ាត់ :**

១- កន្លែងសម្លាប់មនុស្ស : ភូមិសំអាង ឃុំសំអាង ស្រុកថាឡាបរិវ៉ាត់

២- គុក : ភូមិកោះសាឡយ ឃុំកោះសាឡាយ ស្រុកសៀមបូក ។ ពត៌មាននៃទីតាំងខាងលើនេះបានទទួលមកពីអភិបាលស្រុកថាឡាបរិវ៉ាត់ ឈ្មោះ **ផេង សាមិន** អាយុ ៤៧ឆ្នាំ ក្នុងរបប **ប៉ុល ពត** រស់នៅភូមិស្រែគ្នោត ឃុំស្រែគ្នោត " បច្ចុប្បន្នមានឈ្មោះថា ឃុំថាឡា

បរិវ៉ាត់ " ស្រុកថាឡាបរិវ៉ាត់ ។ ប្រធានភូមិឈ្មោះ **អ៊ឹម** ដែលបានដឹងឮអំពីរឿងនេះ ហើយសព្វថ្ងៃរស់នៅភូមិអន្លង់ក្រមួន ឃុំស្រែឫស្សី ស្រុកថាឡាបរិវ៉ាត់ ។

## សាលាឃុំព្រះរំកិល

ក្នុងឆ្នាំ១៩៧០ អ្នកស្រុករស់នៅឃុំព្រះរំកិល មួយចំនួនធំ បានភៀសខ្លួនទៅកាន់ប្រទេសឡាវ ។ អ្នកដែលនៅសល់ត្រូវបានពួកខ្មែរក្រហមជំលៀសទៅកាន់ភូមិអូររ៉ៃ ឃុំអូររ៉ៃ និងភូមិកោះសាឡាយ ឃុំក្រាំងចាប ស្រុកថាឡាបរិវ៉ាត់ ។ ឃុំព្រះរំកិលទាំងមូល ត្រូវបានជំនួសដោយជនជាតិភាគតិចមកពីខេត្តរតនៈគីរី ។ ក្នុងឆ្នាំ១៩៧៩ អ្នកស្រុកព្រះរំកិលទាំងអស់បានវិលមកកាន់ភូមិកំណើតរបស់ខ្លួនវិញ ។

## ទីតាំងប្រល័យពូជសាសន៍ :

១~ **ភូមិឆែប** ឃុំព្រះរំកិល ស្រុកឆែប " បច្ចុប្បន្នស្រុកថាឡាបរិវ៉ាត់ " ។

សាក្សី : **ជុំ ផង់** ភេទ ស្រី អាយុ ៤២ឆ្នាំ សព្វថ្ងៃរស់នៅភូមិក្រោម ឃុំព្រះរំកិល បានរាយការណ៍ថា ក្នុងឆ្នាំ១៩៧០ ពួកខ្មែរក្រហមបានយកប្តីរបស់គាត់ទៅសម្លាប់នៅភូមិឆែប ដែលទីនេះគឺជាទីកន្លែងឃុំឃាំងផង ។ ក្នុងឆ្នាំ១៩៧៨ ពួកខ្មែរក្រហមក៏បានយកឪពុករបស់គាត់ទៅសម្លាប់ទីនោះដែរ ។

## បទសំភាសន៍យកពត៌មានជាមួយអតីតៈគណៈស្រុកតំបន់១០៣ ញៀម សុខន ហៅម៉េង

" ភ្ជាប់ជាមួយនឹងប្រវត្តិសង្ខេបមួយច្បាប់ និងរូបថត "

**ម៉េង** ជាលេខារបស់សមមិត្ត **ចាន់ សារ៉េត** ដែលជាសមាជិកមជ្ឈឹមបក្សកុំម្មុយនីស្តកម្ពុជា **ចាន់ សារ៉េត** ធ្លាប់ធ្វើជាជំទប់ទី១នៅខេត្តស្វាយរៀង ហើយក៏ធ្លាប់ធ្វើជាអភិបាលស្រុកស្វាយរៀង ដែរ ។ **ចាន់ សារ៉េត** ក៏ធ្លាប់ជាបេក្ខជនតំណាងរាស្ត្រខេត្តកោះកុង ក្នុងឆ្នាំ១៩៥៥ ។ **ម៉េង** បានរាយការណ៍ថា នៅក្នុងជួរមជ្ឈឹមបក្ស មានសមាជិកប្រហែល ១៥រូបតែប៉ុណ្ណោះទេ គឺ :

១- **ប៉ុល ពត** សមមិត្ត **ពូក**

២- **ជូ ជេត** អតីត : ចាងហ្វាងកាសែតអ្នកជាតិនិយម

៣- **សោ ភឹម**

៤- **កុយ ធួន** ហៅ **ធុច**

៥- **ម៉ី សាន** ហៅ **យ៉ា** មកពីភូមិភាគ ១០៨

៦- **ចាន់ សារ៉េត** ហៅ **ម៉ាន**

៧- **ឈឹត ជឿន** ហៅ **ម៉ុក**

៨- **កង ចាប** ហៅ **សែ**

៩- **អៀង សារី** ហៅ **វ៉ាន់**

១០- **ខៀវ សំផន**

១១- **រស់ ញឹម**

១២- **នួន ជា**

១៣- **ស៊ឹង ខ៊ុកម៉ិញ** ហៅ អាចារ្យមៀន

១៤- **កែវ មាស**

១៥- **វ៉ន វ៉េត**

**ម៉េង** បាននិយាយថា សមាជិកមជ្ឈិមបក្ស ប្រហែលមានលើសពីនេះ ប៉ុន្តែគេចាំបានតែ ១៥ រូប ។ គ្រប់តំបន់ទាំងអស់ដែលមានសមាជិកមជ្ឈិមរស់នៅ គឺជាតំបន់ពិសេស ។ តំបន់ពិសេស គឺជាមូលដ្ឋានបង្អែក ជាកន្លែងដែលរំដោះបានទាំងស្រុង និងជាកន្លែងកសាងប្រជាជនអោយបានល្អឥតខ្ចោះ ។ **ម៉េង** ចាំបានថា នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៧០ ខ្មែរក្រហម១ក្រុម ដែលមានឈ្មោះ **ចាន់ សារ៉េត** ហៅ **ម៉ាន** ឈ្មោះ **ប៊ូ ផាន** ហៅ **ហង្ស** ដែលជាអតីតចាងហ្វាងកាសែតដំណឹងថ្មី និងឈ្មោះ **ផន** ហៅ **ម៉ៅ** ដែលរស់នៅក្នុងភូមិជាមួយគ្នា បានចូលមកផ្ទះរបស់ខ្លួននៅក្នុងយប់នោះ ។ ក្នុងគោលបំណងហៅឪពុករបស់គាត់ ដែលជាទាហានឥស្សរៈអោយចូលទៅក្នុងព្រៃ ដើម្បីតស៊ូប្រឆាំងនឹងចក្រពត្តិអាមេរិកាំង ។ ប៉ុន្តែពេលនោះ ឪពុករបស់គាត់មានជំងឺ ក៏បញ្ជូនគាត់មកជំនួសវិញ ។ ឪពុករបស់ **ម៉េង** ឈ្មោះ **ញៀម ណាក** ជាសាច់សារលោហិតជាមួយនឹងឯកឧត្តម **អ៊ិន តាំ** ប្រធានគណបក្សប្រជាធិបតេយ្យក្នុងអំឡុងពេលបោះឆ្នោត ១៩៩៣ ។

**រដ្ឋបាល :**

លេខាមជ្ឈឹមបក្សមានតួនាទីកាន់កាប់ការងារថ្នាក់ស្រុក រីឯអនុលេខាមជ្ឈឹមបក្ស កាន់ការងារនៅថ្នាក់ឃុំ ។ សមាជិកដែលប្រមូលមកពីគ្រប់ឃុំទាំងអស់ ជាគណបក្សស្រុក ។

**សន្តិសុខ :**

ក្រុមដែលពាក់ព័ន្ធក្នុងការសម្លាប់មនុស្សមាន :

- ឈ្លបភូមិ
- ឈ្លបឃុំ
- យោធាស្រុក

ចំណែកឯយោធាតំបន់ និងយោធាភូមិភាគ ពុំមានការទាក់ទងនឹងការសម្លាប់ប្រជាជនទេ ព្រោះគឺជាអ្នកដែលប្រយុទ្ធការពារនៅតាមទល់ដែន ថៃ វៀតណាម និងលាវ ។

- ស្រុកសៀមបូក មានឈ្មោះថា ស១១
- ស្រុកព្រះរំកិល មានឈ្មោះថា ស១២
- ស្រុកឆែប មានឈ្មោះថា ស២៨

** " ស " មានតែនៅក្នុងតំបន់ពិសេស ឬ តំបន់ដែលរំដោះបានទាំងស្រុង ។

គណៈតំបន់ ១០៣ " ថ្មី " ឈ្មោះ **ឌុច** ហៅ **ឃាន** ជាអតីតៈសាស្ត្រាចារ្យគីមី រូបវិទ្យា នៅវិទ្យាល័យខេត្តកំពង់ចាម ហើយជាអ្នកដែលជិតស្និតបំផុត ជាមួយឯកឧត្តម **គាត ឈុន** រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ បច្ចុប្បន្ននេះ ។

**របៀបបញ្ជូនឯកសារក្នុងតំបន់រំដោះ :**

សរសេរពតិមានលើក្រដាសស៊ីម៉ង់ ដោយទឹកខ្មៅពិសេសម្យ៉ាងមកពីប្រទេសចិន ដែលយើងពុំអាចមើលឃើញអក្សរនៅលើក្រដាសនោះទេ ។ រួចច្រកសំបុត្រនោះទៅក្នុងបំពង់ឫស្សីមួយអោយដល់និរសារ យកទៅកាន់គោលដៅ ។ ដើម្បីអានសំបុត្រអ្នកដែលទទួលសំបុត្រនេះ មានទឹកខ្មៅម្យ៉ាងជ្រលក់សំបុត្រអោយសើមរួចយកទៅហាលថ្ងៃ ទើបគេអាចអានអក្សរបាន ។ **ម៉េង** ជាអ្នកសរសេររបាយការណ៍អំពីសកម្មភាពស្រុក ដែលទាក់ទងទៅនឹងបញ្ហាសន្តិសុខ នយោបាយ និងសតិអារម្មណ៍ប្រជាជន ផ្ញើទៅមជ្ឈឹមបក្ស ដែលមាន **ប៉ុល ពត** និង **នួន ជា** ជាអ្នកទទួល ។ **ប៉ុល ពត** ពុំដែលផ្ញើលិខិតបញ្ជាអោយសម្លាប់ប្រជាជនខ្មែរទេ ប៉ុន្តែបានបញ្ជាអោយសម្លាប់វៀតណាមទាំងអស់ និងអ្នកដែល

ទៅរៀននៅវៀតណាមខាងជើង ចំនួន ២,៥០០នាក់ ជាមួយអាចារ្យមៀន ។ បញ្ហានេះ **ប៉ុល ពត** បានប្រកាសជាចំហរ នៅក្នុងឆ្នាំ១៩៧៥ ។ **ម៉ែង** បានរាយការណ៍ថា **នួន ជា** ចុះមកបញ្ជូរអោយសម្លាប់ផ្ទាល់ ។ កម្រធ្វើជាលិខិតស្នាមណាស់ ។ **ម៉ែង** បញ្ជាក់ថា គណៈតំបន់មានសិទ្ធិសម្រេចក្នុងការសម្លាប់មនុស្ស ដោយពុំចាំបាច់ទទួលបញ្ជាពីមជ្ឈិមទេ ។ ជាទូទៅគណៈស្រុក ឃុំ និងភូមិ ធ្វើសេចក្តីរាយការណ៍ទៅតំបន់អំពីមនុស្សដែលសង្ស័យថា ក្បត់នឹងអង្គការ ។ ក្រោយមកគណៈតំបន់ឆ្លើយតបវិញថាកំទេចចោល ឬ វាយកំទេចអោយហ្មត់ ដែលមានន័យថា សម្លាប់ចោល ។ សមាជិកមជ្ឈិមបក្សជួបជុំគ្នា ៦ខែម្តង ដើម្បីធ្វើការសម្រេចចិត្តលើការងារទូទៅ ។ បញ្ជីសម្លាប់របស់ **ប៉ុល ពត** ច្រើនតែផ្ញើទៅអោយគណៈតំបន់ ដោយខ្ទាស់ភ្ជាប់ទៅនឹងសៀវភៅទង់បដិវត្តន៍ជារៀងរាល់ខែ ។ **ម៉ែង** បាននិយាយថា គាត់ពុំដែលហ៊ានអានសំបុត្រទាំងនោះអោយចប់ចុងចប់ដើមទេ ។ គាត់ធ្លាប់បានជួប **ប៉ុល ពត** នៅក្នុងឆ្នាំ១៩៧៤ គឺនៅពេលដែលសម្តេច **សីហនុ** យាងមកភូមិថ្នារ ឃុំថ្នារ ស្រុកជ័យសែន ខេត្តព្រះវិហារ ។ កាលនោះ ថ្នារគឺជាមូលដ្ឋានធំជាងគេបង្អស់ក្នុងទឹកដីរំដោះ ក្នុងចំណោមមូលដ្ឋានធំទាំងបី ។

១- **ថ្នារ** សមមិត្ត **ម៉ាន** លេខាតំបន់ ជាអ្នកគ្រប់គ្រង ប្រពន្ធឈ្មោះ **ស៊ុន** ជាអ្នកទទួលបន្ទុកនារី

២- **ត្រលាច់** ស្ថិតនៅភូមិ ត្រលាប់ ស្រុករវាងខេត្តព្រះវិហារ សមមិត្ត **ហង្ស** អនុលេខាតំបន់ ជាអ្នកគ្រប់គ្រង

៣- **ឆែម** ឃុំព្រះរំកិល ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង សមមិត្ត **ផង់** សមាជិកតំបន់ ជាអ្នកគ្រប់គ្រង

**ម៉ែង** បានរាយការណ៍ថា **ចាន់ សារ៉េត** ធ្វើការសម្រេចក្នុងការសម្លាប់ប្រជាជន ដោយឈរលើមាគ៌ាអង្គការ " ពាក្យស្លោក " ៣ ចំណុច គឺ :

១- អ្នកមិនទៅជាមួយ ក៏គេមិនថាអ្វី ប៉ុន្តែកុំអោយប្រឆាំង

២- នាយទុនកុំប្រ្ងដ៉រ នាយទុនជាតិ កសិករមាន បញ្ញាជន អនុជន ព្រះសង្ឃ " ជាកំលាំងដែលប្រមូលខាងក្រៅ ជាពិសេសកសិករ "

៣- ចំពោះក្រុមប្រតិកិរិយា គឺមិនទុក " ជំពូកនេះមាន *CIA, KGB* "

ប្រសិនបើមានសេចក្តីរាយការណ៍ណាមួយអំពីជនណាមួយ ដែលធ្លាក់ចូលក្នុងចំណុចទាំង ៣ ខាងលើនេះ នឹងត្រូវយកទៅសម្លាប់ចោល ។ បើមិនធ្លាក់ចូលទេនោះ សមមិត្ត **ចាន់ សារ៉េត** តែងតែបញ្ជូនអោយឈ្លបភូមិ ឬ ឈ្លបស្រុក ធ្វើការតាមដានបន្តទៀត និងអប់រំ ។

**លេខាផ្ទាល់របស់ ប៉ុល ពត :**

លោក **ប៉ុល ឌីកុមារ** *( Pok De Koma )* ហៅ **ម៉ង់** មកពីប្រទេសបារាំង ជាលេខាផ្ទាល់របស់ **ប៉ុល ពត** ក្នុងឆ្នាំ១៩៧០ ទទួលបន្ទុកស្ថានីយ៍វិទ្យុនៅមន្ទីរ " ប ២០ " ដែលជាមន្ទីរមជ្ឈឹម តាំងនៅព្រៃកៅស៊ូ ឃុំបូកខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម ។

* " ប " មន្ទីរមជ្ឈឹម

* " ស " មិនដឹងថា មានន័យអ្វីទេ

* " អ " មានន័យថា អង្គភាព

" អង្គភាព ១២ ជា សហករភារូបនីយកម្ម "

**បញ្ជាអោយសម្លាប់ :**

ឯកសារបញ្ជាឱ្យសម្លាប់មាននៅក្នុងសៀវភៅទង់ក្រហម ដែលមាន **នួន ជា** និង **ប៉ុល ពត** ជាអ្នកនិពន្ធ ។ **ម៉ែង** បានអះអាងថា សំដីដែល **នួន ជា** និង **ប៉ុល ពត** និយាយគឺដូចមាននៅក្នុងឯកសារទង់បដិវត្តន៍ ។ **ម៉ែង** បាននិយាយថា **ខៀវ សំផន** ពុំដឹងរឿងច្រើនទេ ព្រោះបានចូលជាសមាជិកមជ្ឈឹមបក្សក្នុងឆ្នាំ១៩៧៤ ។ **ខៀវ សំផន** ធ្លាប់មានរហស្សនាមថា " ប្រធានមន្ទីរដាំស្លែ " ហើយតែងតែ ត្រូវបានឃ្លាំមើលជានិច្ច ដោយ **នួន ជា** ។

**អង្គការ :**

**ម៉ែង** បាននិយាយថា " ពាកថាស្មើទៅអង្គការលើ " មានន័យថា ស្មើទៅគណៈតំបន់ ។

**ពាក្យស្លោក :** អង្គការតំណាងអោយការត្រូវ និងការល្អ

- យើងជាប្រជាធិបតេយ្យ ប៉ុន្តែមិនមែនប្រជាធិបតេយ្យប្រមូលផ្តុំទេ ។ ប្រជាធិបតេយ្យប្រមូលផ្តុំ គឺផ្តាច់ការ ។
- បើចង់បំផ្លាញដើមចេក, កុំកាត់ចុងវា " ព្រោះវាលាស់មកវិញ " ។ ១៩៧១ : **នួន ជា** បានបញ្ជាអោយសម្លាប់ខ្មែរទាំងអស់ ដែលទាក់ទងនឹងអាចារ្យមៀន ដូចជា **ម៉ាន, ហង្ស សុន, ម៉ុន ចាន់,** ប្រធានស្រុកនៅមណ្ឌលគីរី និងរូបគាត់ផ្ទាល់ ។

**មូលហេតុនៃការបដិវត្តន៍ :**

- **ម៉ែង** បានយល់ថា មានការជិះជាន់នៅក្នុងរបបសក្តិភូមិ ។ **ម៉ែង** ហៅថា " ទុរគតិភាវូបនីយកម្ម " ។ មានអ្នកមាន មានអ្នកក្រ ។ ខ្មែរក្រហមបានលើកចំណុចនេះមកឃោសនាដល់អ្នកស្រុក និងបង្កជំលោះផ្ទៃក្នុងអោយកាប់សម្លាប់គ្នាឯង ។ រួចជនមួយក្តាប់តូចក្តោបយកអំណាចក្នុងដៃ ដេកស៊ីស្រួល ។
- **ម៉ែង** និយាយថា **ខៀវ សំផន** មានរូបភាពស្អាតស្អំខាងក្រៅ តែធាតុពិតគឺ ជាអ្នកចូលរួមចំណែកបដិវត្តន៍ដ៏សំខាន់ជាមួយ **ប៉ុល ពត** ។

**តាម៉ុក :**

**ម៉ុក** គឺជាមនុស្សទុកចិត្តរបស់ **ប៉ុល ពត** ហើយមានអំណាចណាស់ ។ **ម៉ុក** ជាមនុស្សមានប្រជាប្រិយភាពជាមួយអ្នកស្រុកដែរ ។ **ម៉ែង** បាននិយាយថាបដិវត្តន៍ខ្មែរក្រហមពុំមានគុក ប៉ុន្តែក្រោយពេលដែល **ម៉ុក** មានអំណាចធំ គេក៏បង្កើតអោយមានគុក ប្រហែលជានៅក្នុងឆ្នាំ១៩៧៧ ។ ហើយការសម្លាប់រង្គាល ក៏ចាប់ផ្តើមមានតាំងពីពេលនោះមក ។ ប្រពន្ធ **ម៉ែង** ដែលមកដេកព្យាបាលជំងឺរលូតកូន នៅមន្ទីរពេទ្យភ្នំពេញ ក្នុងរវាងឆ្នាំ១៩៧៧ នោះ បានឃើញគុក និងការសម្លាប់ធំៗដោយផ្ទាល់ភ្នែក ។

**សេចក្តីសន្និដ្ឋាន :**

- ខេត្តស្ទឹងត្រែង គឺជាខេត្តមានអំណោយផលគ្រប់យ៉ាង ដល់ជនបដិវត្តន៍ ឬ ក្រុមឧទ្ទាមសំរាប់លាក់ខ្លួនរស់នៅ និងវាយឆ្មក់របៀបទ័ពព្រៃ ។ ការវាយប្រហារក្នុងលក្ខណៈទ្រង់ទ្រាយធំៗ គឺពុំអាចធ្វើទៅកើតទេ ដោយចរន្តទឹកខ្វាត់ខ្វែង ប្រទាក់ក្រឡា បង្កលក្ខណៈលំបាក ក្នុងការដឹកជញ្ជូន សព្វយ៉ាង ។
- ប្រជាជនខេត្តស្ទឹងត្រែង ពិតមែនស្ទើរតែទាំងអស់ជាអ្នកមូលដ្ឋានចាស់ ប៉ុន្តែគេមាន ភាពទន់ភ្លន់ និងឯកោ ។
- អំពើប្រល័យពូជសាសន៍នៅខេត្តស្ទឹងត្រែង ហាក់ដូចជា ធ្វើឡើងដោយមនុស្សមកពីតំបន់ផ្សេងៗទៀត ដូចជា តំបន់មណ្ឌលគីរី និងរតនៈគីរី និងភូមិភាគនិរតី ។ ការត្រឡប់ទៅកាន់ខេត្តស្ទឹងត្រែងម្តងទៀត ក្នុងរដូវប្រាំងនេះ ដើម្បីធ្វើការស្រាវជ្រាវជាលំអិតលើរណ្តៅសព និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ខ្មែរក្រហមគឺ ជាការចាំបាច់មួយដែលខានពុំបាន ។